

# ការជួយ ដោយឲ្យខ្មៅដៃម្ដងមួយ។

ដោយ ខេឡិប អេច អាយុ ១០ ឆ្នាំ ប្រទេសអាល្លឺម៉ង់

វាបានចាប់ផ្ដើម នៅពេលស្ដេករបស់ខ្ញុំបានរៀបចំគម្រោងមួយដើម្បីជួយជនភៀសខ្លួន ។ ខ្ញុំពិតជាចូលចិត្តគម្រោងនោះណាស់ ដូច្នេះខ្ញុំបានសូមឲ្យម្ដាយខ្ញុំ ប្រាប់គ្រូបង្រៀននៅសាលាខ្ញុំអំពីរឿងនោះ ហើយគ្រូបង្រៀនរបស់ខ្ញុំចង់ធ្វើអ្វីមួយជាមួយសិស្សថ្នាក់ទីបួន ។ ដើម្បីរៀបចំគំរូសម្រាប់គម្រោងនោះ ម៉ែឪ ជាប្អូនស្រីខ្ញុំ និងខ្ញុំបានដើរពីផ្ទះមួយទៅផ្ទះមួយទៀត ដើម្បីសូមការបរិច្ចាគ ។

ថ្ងៃដែលទន្ទឹងរង់ចាំនោះបានមកដល់ ដើម្បីបង្ហាញគម្រោងនោះដល់សិស្សថ្នាក់ទីបួនទាំងអស់ ។ ខ្ញុំមានអារម្មណ៍ភ័យបន្តិច ។ ប្រាកដណាស់ គឺថាខ្ញុំភ័យខ្លាំងតែម្ដង ប៉ុន្តែខ្ញុំបានធ្វើអស់ពីសមត្ថភាព ។ ខ្ញុំបានប្រាប់ដល់សិស្សថ្នាក់ទីបួនផ្សេងទៀតអំពីអ្វីដែលយើងត្រូវការ សម្រាប់កញ្ចប់សិក្សាដល់ជនភៀសខ្លួន ។ ខ្ញុំបានប្រាប់អំពីរបៀបដែលយើងបានដើរពីផ្ទះមួយទៅផ្ទះមួយទៀត ហើយខ្ញុំបានអញ្ជើញពួកគេឲ្យព្យាយាមធ្វើអ្វីដែលប្រសើរជាងខ្ញុំថែមទៀត ដើម្បីរៃអង្គាសប្រាក់ជួយដល់គម្រោងនោះ ។ ទាំងអស់រួមគ្នា យើងបានធ្វើកញ្ចប់សិក្សាជាង ១០០ កញ្ចប់ ។ យើងបានដាក់សៀវភៅកំណត់ហេតុ ខ្មៅដៃ និងសម្ភារសិក្សាផ្សេងទៀត ។ យើងក៏បានបន្ថែមសារខ្លីមួយដែលនិយាយ « សូមស្វាគមន៍មកកាន់ប្រទេសអាល្លឺម៉ង់ » ។

ម្ដាយរបស់ខ្ញុំ និងខ្ញុំបានយកកញ្ចប់នោះទៅកាន់ជំរំជនភៀសខ្លួន ។ ខ្ញុំពុំអាចនិយាយថា ជំរំនោះស្អាតឡើយ ប៉ុន្តែនៅទីនោះមានកន្លែងលេងកម្សាន្ត និងកន្លែងសម្រាប់ការសិក្សា ។ មានរថភ្លើងមួយនៅជិតជំរំនោះដែលមានសំឡេងឮខ្លាំងណាស់ ហើយក្មេងៗបានប្រាប់ខ្ញុំថា វាមានសំឡេងដូចយន្តហោះចម្បាំង ហោះកាត់ប្រទេស ស៊ីរី និងកន្លែងផ្សេងៗទៀត ។ ប្រហែលវាឮសំឡេងដូចគ្រាប់ប្លោង ចំពោះក្មេងៗដែលបានឮវានៅក្នុងប្រទេសកំណើតរបស់ខ្លួន ។

ខ្ញុំបានជួបក្មេងៗពីរបីនាក់នៅជំរុំនោះ ដែលមានអាយុដំណាលខ្ញុំ រួមមានដានីយ៉ែល ជាអ្នកពូកែលេងអុកផងដែរ ។ ស្ដាយណាស់ ខ្ញុំពុំបានលេងអុកជាមួយគាត់ឡើយ ព្រោះខ្ញុំចូលចិត្តលេងអុកណាស់ ប៉ុន្តែពួកគេបានអញ្ជើញខ្ញុំឲ្យលេងបាល់ទាត់ និងពីងប៉ុងវិញ ។ ក្មេងៗទាំងនោះបានប្រាប់ខ្ញុំថា ពួកគេនឹកផ្ទះណាស់ ហើយពួកគេពិតជាចង់ចេញពីជំរំនេះ ហើយទៅរៀនវិញ ។

បន្ទាប់ពីយើងបានលេងបាល់ទាត់ និងពីងប៉ុងហើយ យើងបានឲ្យកញ្ចប់សិក្សានោះទៅពួកគេ ។ ខ្ញុំមានអារម្មណ៍ល្អ ដែលខ្ញុំអាចធ្វើទង្វើល្អដល់ក្មេងៗដែលរស់នៅក្នុងជំរំនោះ ។ ■



គំនូរព្រាងដោយ អាប៊ែល ស្កុត